**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ......០១៤/២០......**ក.ប**/ស.ណ.ន.ខ.ល

## សេចក្តីណែនាំ
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារ, ការចុះឈ្មោះចូលរៀនជំនាញទន់ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើមដោយសារជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរកូវីដ-១៩

យោងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់លើវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដែលខ្វះវត្ថុធាតុដើមពីប្រទេសផ្គត់ផ្គង់វត្ថុធាតុដើម ដោយសារប្រទេសនោះរងផលប៉ះពាល់ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរកូវីដ-១៩ (CoVid-19) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង, ម្ចាស់ឬនាយករោងចក្រ, និងកម្មករនិយោជិត អំពីនីតិវិធីសុំព្យួរកិច្ចសន្យាការងារ, ការចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់, និងការស្នើសុំផ្អាកបង់ភាគទាននិងការបន្តផ្តល់តាវកាលិករបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដូចខាងក្រោម៖

### ក-ការស្នើសុំព្យួរកិច្ចសន្យាការងារ

យោងស្មារតីនៃមាត្រា៧១ និងមាត្រា៧២នៃច្បាប់ស្តីពីការងារ រោងចក្រដែលខ្វះខាតសម្ភារធ្ងន់ធ្ងរឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពផលិតកម្មណាមួយ នោះភាគីពាក់ព័ន្ធត្រូវបំពេញតាមនីតិវិធីដូចខាងក្រោម៖

សម្រាប់ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- ដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ទៅនាយកដ្ឋានអធិការកិច្ចការងារសម្រាប់រោងចក្រនៅរាជធានីភ្នំពេញ ឬទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សម្រាប់រោងចក្រនៅបណ្តាខេត្ត ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh
- រៀបចំឱ្យមានការពិភាក្សា និងពន្យល់ដល់កម្មករនិយោជិតអំពីមូលហេតុនៃការស្នើសុំព្យួរកិច្ចសន្យាការងារ និងការផ្តល់ប្រាក់ឧបត្ថម្ភក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ដែលក្នុងករណីចំពោះមុខនេះ គឺស្មើនឹង ៤០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០

សូមទាញយកឯកសារតាម QR Code នេះ

ឬតាម Link នេះ https://bit.ly/32AJpJe



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- រៀបចំឱ្យមានឯកសារព្រមព្រៀងជាលាយលក្ខណ៍អក្សរ ជាមួយតំណាងកម្មករនិយោជិត អំពីនីតិវិធីនៃការបើកផ្ដល់ប្រាក់ឧបត្ថម្ភរបស់និយោជក (៤០% នៃ ១៩០ដុល្លារអាមេរិក)
- រៀបចំបញ្ជីឈ្មោះកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារ ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្ដីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh ។

សម្រាប់នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវ៖

- រៀបចំក្រុមអន្តរាគមន៍ពិសេសយ៉ាងតិច ៥ក្រុម ក្នុងនាយកដ្ឋាន ឬមន្ទីរនីមួយៗ ជាពិសេសមន្ទីរដែលមានទីតាំងរោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដើម្បីតាមដានព័ត៌មានពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ និងត្រៀមចុះពិនិត្យតាមបណ្ដាទីតាំងរោងចក្រ ដែលដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារ
- ចុះទៅដល់ទីតាំងរោងចក្រ ដើម្បីពន្យល់សម្របសម្រួលដល់ភាគីពាក់ព័ន្ធអំពីនីតិវិធីនៃការព្យួរកិច្ចសន្យាការងារនេះ ក្នុងរយៈពេល ២៤ម៉ោង នៃម៉ោងធ្វើការ បន្ទាប់ពីបានទទួលសំណើសុំព្យួរកិច្ចសន្យាការងារពីម្ចាស់ ឬនាយករោងចក្រ
- ចេញលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ (ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ និងទី៥ នៃសេចក្ដីណែនាំនេះ) ក្នុងរយៈពេល ២៤ម៉ោង ក្រោយកម្មករនិយោជិតនិងនិយោជកបានបំពេញគ្រប់នីតិវិធី និងមានឯកសារព្រមព្រៀងគ្នាជាមួយតំណាងកម្មករនិយោជិត
- ចម្លងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ ជូនបេឡាជាតិសន្តិសុខសង្គម, ទីភ្នាក់ងារជាតិមុខរបរ និងការងារ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, និងរដ្ឋបាលរាជធានី-ខេត្ត ដែលពាក់ព័ន្ធ។

សម្រាប់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖

- រៀបចំក្រុមអន្តរាគមន៍ពិសេសយ៉ាងតិច ៥ក្រុម នៅរាជធានីភ្នំពេញ និងតាមមជ្ឈមណ្ឌលការងារនីមួយៗ ជាពិសេសមជ្ឈមណ្ឌលការងារ ដែលស្ថិតក្នុងខេត្តមានទីតាំងរោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដើម្បីចុះជាមួយមន្ត្រីអធិការកិច្ចការងារនៃនាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរ រៀបចំទទួលចុះឈ្មោះកម្មករនិយោជិតចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាញទន់។

**ខ-ការចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាញទន់**

សម្រាប់ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- សហការ និងជួយជូនដំណឹងដល់កម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យចុះឈ្មោះចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាញទន់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមផ្ទាល់ របស់រាជរដ្ឋាភិបាលចំនួន ២០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០

- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់កម្មករនិយោជិតចុះឈ្មោះចូលរៀនជាមួយមន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ផ្តល់ទីតាំងសម្រាប់ដំណើរការវគ្គបណ្តុះបណ្តាលនៅក្នុងរោងចក្រ។

**សម្រាប់កម្មករនិយោជិត ត្រូវ៖**

- ចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមផ្ទាល់របស់រាជរដ្ឋាភិបាល ចំនួន ២០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០។
- ចូលរៀនឱ្យបានទៀងទាត់ទៅតាមកម្មវិធីបណ្តុះបណ្តាល។

**សម្រាប់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖**

- សម្របសម្រួលជាមួយរោងចក្រ ក្នុងការរៀបចំដំណើរការវគ្គបណ្តុះបណ្តាល
- ជូនដំណឹងដល់កម្មករនិយោជិតអំពីកាលវិភាគ និងកម្មវិធីបណ្តុះបណ្តាល
- ផ្តល់ការបណ្តុះបណ្តាលឱ្យមានប្រសិទ្ធភាព និងគុណភាព
- រៀបចំ និងគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃរបស់កម្មករនិយោជិតដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល។

**គ-ការស្នើសុំផ្អាកបង់ភាគទាន និងការបន្តផ្តល់តាវកាលិករបស់ ប.ស.ស.**

- ម្ចាស់ ឬនាយករោងចក្រត្រូវធ្វើលិខិតជូនដំណឹងអំពីការផ្អាកបង់ភាគទានមក ប.ស.ស. ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh
- ក្នុងអំឡុងពេលមកចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ កម្មករនិយោជិតនឹងបន្តទទួលបានតាវកាលិក ផ្នែកហានិភ័យការងារពី ប.ស.ស.
- ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនឹងបន្តទទួលបានតាវកាលិក ផ្នែកថែទាំសុខភាពពី ប.ស.ស. និងប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូនពីរាជរដ្ឋាភិបាល (៤០ម៉ឺនរៀលសម្រាប់កូនម្នាក់, ៨០ម៉ឺនរៀលសម្រាប់កូនភ្លោះពីរនាក់, និង១,២លានរៀលសម្រាប់កូនភ្លោះបីនាក់ និងទទួលបានប្រាក់ឧបត្ថម្ភរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំនួន ៥លានរៀល)។

**ឃ-ការផ្សព្វផ្សាយលទ្ធផលការងាររបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា**

- លេខាធិការដ្ឋាននៃគណៈកម្មការប្រឹក្សាការងារ (SLAC) ត្រូវសហការជាមួយនាយកគម្រោង និងភាគីពាក់ព័ន្ធនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ដើម្បីផ្សព្វផ្សាយអំពីវឌ្ឍនភាពវិជ្ជមានជាបន្តបន្ទាប់នៃលក្ខខណ្ឌការងារ សិទ្ធិការងារ និងសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជាដល់កម្មករនិយោជិត សារព័ត៌មានជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា

- លេខាធិការដ្ឋាននៃគណៈកម្មការប្រឹក្សាការងារ (SLAC) ត្រូវសហការជាមួយបណ្តាញព័ត៌មាននានា ផលិតរូបភាព វីដេអូឃ្លីប និងខិត្តប័ណ្ណ អំពីចំណាប់អារម្មណ៍របស់កម្មករនិយោជិត និងអ្នកប្រើប្រាស់ផលិតផលពីកម្ពុជា ចំពោះភាពកាន់តែប្រសើរឡើងនៃលក្ខខណ្ឌការងារ សិទ្ធិការងារ និងសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជា ដែលកើតចេញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការភ្ជាប់ការធ្វើពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ និងការអនុញ្ញាតឱ្យមានគម្រោង ILO-BFC នៅកម្ពុជា ដែលបច្ចុប្បន្នបានក្លាយទៅជាគំរូសម្រាប់អង្គការអន្តរជាតិខាងការងារ (ILO) យកទៅប្រើប្រាស់ និងលើកទឹកចិត្តបណ្តាប្រទេសផ្សេងទៀតឱ្យយកគំរូតាមកម្ពុជា។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង, ម្ចាស់ ឬនាយករោងចក្រ, និងកម្មករនិយោជិតនៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៦កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងពាណិជ្ជកម្ម
- គ្រប់អង្គការវិជ្ជាជីវៈ

  "ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១៖ លិខិតស្នើសុំព្យួរនៅរាជធានីភ្នំពេញ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន** ..........................................................................................................
លេខបញ្ជីពាណិជ្ជកម្ម៖ .....................................................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ........................................................................
អាសយដ្ឋាន ៖.................................................................................................................
ទូរសព្ទលេខ៖ ....................................... Email៖ ..................................................................។

**សូមគោរពជូន**
**លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**កម្មវត្ថុ៖** សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន.............នាក់រយៈពេល .........ខែ។
**យោង៖** មាត្រា៧១និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ដោយសារតែក្រុមហ៊ុនយើងខ្ញុំខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត..................។ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន........នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន.......នាក់ រយៈពេល ........ខែ ដោយគិតចាប់ពីថ្ងៃទី........... ខែ....... រហូតដល់ថ្ងៃទី....... ខែ.......ឆ្នាំ២០២..............។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន .......ដុល្លារអាមេរិក ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេច។
សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២...
ហត្ថលេខា និងត្រា
នាយក

**សូមភ្ជាប់មកជាមួយ:**
- កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជកចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ ច្បាប់ និងជា Soft Copy (Ms Excel)
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- បណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន** ..........................................................................................................
លេខបញ្ជីពាណិជ្ជកម្ម៖ ..................................................................................................
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ..............................................................................
អាសយដ្ឋាន ៖...................................................................................................................
ទូរសព្ទលេខ៖ ........................................ Email៖ ..............................................................។

**សូមគោរពជូន**
**លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត**.................

**កម្មវត្ថុ៖** សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន............នាក់រយៈពេល .........ខែ។
**យោង៖** មាត្រា៧១និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា ដោយសារតែក្រុមហ៊ុនយើងខ្ញុំខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត....................។ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន...........នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន...........នាក់ រយៈពេល ............ខែ ដោយគិតចាប់ពីថ្ងៃទី ......... ខែ......... រហូតដល់ថ្ងៃទី ...... ខែ......ឆ្នាំ២០២...។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន .........ដុល្លារអាមេរិក ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងសម្រេច។
សូម **លោកប្រធាន** មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២...
ហត្ថលេខា និងត្រា
នាយក

**សូមភ្ជាប់មកជាមួយ:**
- កិច្ចព្រមព្រៀងរវាងកម្មករនិយោជិតជាមួយនិយោជកចំនួន ៣ច្បាប់
- បញ្ជីឈ្មោះកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- បណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់

*ឧបសម្ព័ន្ធទី៣៖ បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ*

## បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

**ក្រុមហ៊ុន**.......................................................

រយៈពេលព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី....ខែ.....ឆ្នាំ២០២០ដល់ថ្ងៃទី...ខែ...ឆ្នាំ២០២០

| ល.រ | ឈ្មោះកម្មករនិយោជិត | ភេទ | ថ្ងៃខែឆ្នាំកំណើត | បម្រើការនៅផ្នែក | លេខបណ្ណសមាជិក ប.ស.ស | លេខសៀវភៅការងារ | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី ....

ថ្ងៃទី ...... ខែ ........ ឆ្នាំ ..........

ហត្ថលេខា និងត្រា

នាយកក្រុមហ៊ុន

**សម្គាល់៖**

-ក្រុមហ៊ុនត្រូវវាយត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ

-ក្រុមហ៊ុនត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File មក Email: info@nea.gov.kh

*ឧបសម្ព័ន្ធទី៤៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ*
*នៅរាជធានីភ្នំពេញ*

**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**
លេខ:.......................កប/អក/អធក.

**ជម្រាបមក**
**លោកនាយកក្រុមហ៊ុន** ..........................................

**កម្មវត្ថុ៖** ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។
**យោង៖** លិខិតលេខ....... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០... របស់ ...........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំ និងការព្រមព្រៀងគ្នារវាងកម្មករនិយោជិតនិងនិយោជក នាយកដ្ឋានអធិការកិច្ចការងារសម្រេចអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន............នាក់ ក្នុងចំនួនកម្មករនិយោជិតសរុប................នាក់ រយៈពេលចំនួន ........ខែ ដោយគិតចាប់ពីថ្ងៃទី....... ខែ........ រហូតដល់ថ្ងៃទី........ ខែ......... ឆ្នាំ២០២...។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឈ្នួលឱ្យបានត្រឹមត្រូវតាមការព្រមព្រៀង។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។ សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២....
**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ចម្លងជូន:**
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលរាជធានីភ្នំពេញ

*ឧបសម្ព័ន្ធទី៩៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារនៅខេត្ត*

**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត.........**

លេខ: ..........................................

**ជម្រាបមក**

**លោកនាយកក្រុមហ៊ុន ...............................................**

**កម្មវត្ថុ៖** ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

**យោង៖** លិខិតលេខ....... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០... របស់ ............។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** ថា បន្ទាប់ពីបាន ពិនិត្យលើការស្នើសុំ និងការព្រមព្រៀងគ្នារវាងកម្មករនិយោជិតនិងនិយោជក មន្ទីរសម្រេចអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន.......នាក់ ក្នុងចំនួនកម្មករនិយោជិតសរុប........នាក់ រយៈពេលចំនួន ........ខែ ដោយគិតចាប់ពីថ្ងៃទី....... ខែ........ រហូតដល់ថ្ងៃទី........ ខែ......... ឆ្នាំ២០២...។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ **លោកនាយក** ត្រូវអនុវត្តការបើកប្រាក់ឈ្នួលឱ្យបានត្រឹមត្រូវតាមការព្រមព្រៀង។។

អាស្រ័យដូចនេះ សូម **លោកនាយក** បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម **លោកនាយក** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស២៥៦....

...................... ថ្ងៃទី ខែ ឆ្នាំ២០២.....

**ប្រធានមន្ទីរ**

**ចម្លងជូន:**

- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- អគ្គនាយកដ្ឋានពន្ធដារ
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- នាយកដ្ឋានអធិការកិច្ចការងារ
- រដ្ឋបាលខេត្ត.............

*ឧបសម្ព័ន្ធទី៦៖ លិខិតជូនដំណឹងផ្អាកការបង់ភាគទាន ប.ស.ស.*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន** ..........................................................................................................................

លេខបញ្ជីពាណិជ្ជកម្ម៖ .....................................................................................................................

លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖ ......................................................................................

អាសយដ្ឋាន ៖...............................................................................................................................

ទូរសព្ទលេខ៖ ....................................... Email៖ ...........................................................................។

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម**

**កម្មវត្ថុ៖** ការជូនដំណឹងអំពីការផ្អាកបង់ភាគទាន ប.ស.ស.។

**យោង៖** លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារលេខ............... ចុះថ្ងៃទី ...... ខែ......ឆ្នាំ ....... របស់ ............។

សេចក្តីដូចមានចែងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ដោយសារតែក្រុមហ៊ុនយើងខ្ញុំខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត.................. ខ្ញុំបានស្នើសុំ និងទទួលបានការអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន........នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន....... នាក់ រយៈពេល ......ខែ ដោយគិតចាប់ពីថ្ងៃទី...... ខែ....... រហូតដល់ថ្ងៃទី....... ខែ.......ឆ្នាំ២០២០។

សេចក្តីដូចបានជម្រាបជូនខាងលើ ខ្ញុំសូមជូនដំណឹងដល់ **ឯកឧត្តមប្រតិភូ** អំពីការផ្អាកបង់ភាគទាន ប.ស.ស. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ តាមស្មារតីសម្រេចរបស់រាជរដ្ឋាភិបាល ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២០

ហត្ថលេខា និងត្រា

នាយក

**សូមភ្ជាប់មកជាមួយ:**

- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ (ច្បាប់ថតចម្លង)